**សុន្ទរកថា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ**

**ថ្លែងក្នុង**

**ពិធីប្រកាសដាក់ឱ្យអនុវត្តនីតិវិធីអនុវត្តចំណាយថវិកាចរន្ត**
**តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
**(FMIS) ទាំងស្រុង ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង**
**ក្រសួងបរិស្ថាន ជាផ្លូវការ**

ទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃ ចន្ទ ៧ រោច ខែ អស្សុជ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០២២

- **ឯកឧត្តម**, **លោកជំទាវ**, **លោក**, **លោកស្រី**;
- **លោក ប្រាយអាន ហូរណារី**, **ទីប្រឹក្សា** - **ប្រធានកិច្ចសហប្រតិបត្តិការ ប្រតិភូនៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា**;
- **តំណាងដៃគូអភិវឌ្ឍន៍**;
- **អង្គពិធីទាំងមូល**, **ជាទីមេត្រី** !

ថ្ងៃនេះ, ខ្ញុំមានសេចក្តីសោមនស្ស ដោយបានមកចូលរួមជាអធិបតី ក្នុងពិធីប្រកាសដាក់ឱ្យអនុវត្ត «**នីតិវិធីអនុវត្តចំណាយថវិកាចរន្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ទាំងស្រុង**» ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងបរិស្ថាន ជាផ្លូវការ ។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាថ្នាក់ដឹកនាំ, មន្ត្រីរាជការ និង តំណាងដៃគូអភិវឌ្ឍន៍ ដែលបានចូលរួមនៅក្នុងពិធីនាថ្ងៃនេះ, ទាំងនៅទីនេះផ្ទាល់ និង នៅក្នុងប្រព័ន្ធវីដេអូអនឡាញពីចម្ងាយ ។

ខ្ញុំសូមថ្លែងអំណរគុណ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS ដែលបានផ្តល់នូវរបាយការណ៍ក្បោះក្បាយ រួមជាមួយនឹងការចាក់បង្ហាញវីដេអូខ្លី រៀបរាប់អំពីការប្រើប្រាស់ប្រព័ន្ធ FMIS សម្រាប់ការអនុវត្តនីតិវិធីអនុវត្តការងារចំណាយថវិកាចរន្តតាមប្រព័ន្ធទាំងស្រុង ដោយមិនមានការធ្វើចរាចរ ឬ **ការប្រើប្រាស់ឯកសារជាក្រដាស** ។ **នីតិវិធីថ្មីនេះនឹងជួយបង្កើនល្បឿនបន្ថែមមួយកម្រិតទៀត** ក្នុងការអនុវត្តនីតិវិធីចំណាយថវិកាចរន្ត ដែលបច្ចុប្បន្នត្រូវចំណាយពេល និង ធនធានច្រើន ក្នុងការអនុវត្តនីតិវិធី ជាពិសេស ដំណើរការបញ្ជូនឯកសារ ជាក្រដាស ចេញពីដំណាក់កាលមួយ ទៅដំណាក់កាលមួយ **ដែលសព្វថ្ងៃតែងហៅថាការរត់ឯកសារ ឬ អ្នករត់ការឯកសារ** ដែលធ្វើឱ្យមានការលំបាក ក្នុងការតាមដាននូវដំណើរការឯកសារ ហើយក្នុងករណីមានកំហុសឆ្គងនោះ នឹងត្រូវរុញឯកសារត្រឡប់មកវិញដើម្បីកែតម្រូវចុះឡើង និង កាន់តែធ្វើឱ្យមានភាពយឺតយ៉ាវ ។

តាមរបាយការណ៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានក្រុមការងារ, ការដាក់ឱ្យអនុវត្តនីតិវិធីថ្មីក្នុងថ្ងៃនេះ ក៏មិនមែនជារឿងថ្មីនោះទេ, ពោលគឺក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចាប់ផ្តើមអនុវត្តមុនគេជាគំរូ ចាប់តាំងពីឆ្នាំ ២០២០ មកម្ល៉េះ ទៅលើចំណាយបៀវត្ស, បន្ទុកបុគ្គលិកផ្សេងៗ ដូចជា ទឹក, ភ្លើង, សោហ៊ុយប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ជាបន្តបន្ទាប់ក៏មានការចូលរួមពីក្រសួង-ស្ថាប័ននៅថ្នាក់ជាតិស្ទើរទាំងអស់ ផ្អែកតាម **ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ២០២០-២០២៥** និង ផែនការពង្រីកការ-អនុវត្តគម្រោង FMIS ជំហានទី ៣ នៅក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ការដកពិសោធន៍នេះ បានផ្តល់នូវមាគ៌ាតម្រង់ទិសជាមូលដ្ឋានដ៏សំខាន់ សម្រាប់ការ-បោះជំហានដ៏ធំបន្ថែមទៀត ក្នុងការពង្រីកការអនុវត្តនីតិវិធីថ្មី សម្រាប់ចំណាយថវិកាចរន្តក្នុងប្រព័ន្ធ FMIS ទាំងស្រុង ដោយត្រូវអនុវត្តនៅដំណាក់កាលដំបូងចេញពី **ក្រសួងចំនួន ២ ជាគំរូ គឺក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងបរិស្ថាន** ក្នុងនាមជាអាណាប័ក ដែលមានអង្គភាពថវិកា និង អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុជាអ្នកអនុវត្ត មុននឹងឈានទៅកាន់ការពង្រីកការអនុវត្តទៅដល់ក្រសួង-ស្ថាប័ន និង អង្គភាពថវិកាផ្សេងទៀត នៅទូទាំងប្រទេស ។ ទន្ទឹមនេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងនាមជាអភិបាលហិរញ្ញវត្ថុ និង គណនេយ្យករសាធារណៈ ក៏នឹងត្រូវចូលរួមអនុវត្តនីតិវិធីថ្មីនេះផងដែរ **ពោលគឺអនុវត្តទាំងស្រុងតាមប្រព័ន្ធ FMIS ចាប់ពីចំណុចចាប់ផ្តើមរហូតដល់ចំណុចចុងក្រោយ** ។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !**

ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ គឺជាចលករដ៏មុតស្រួចរបស់រាជរដ្ឋាភិបាល ក្នុងការកែលម្អប្រព័ន្ធហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា ដោយមានប្រព័ន្ធ FMIS គឺជាឧបករណ៍ស្នូលមិនអាចខ្វះបាន ក្នុងការគាំទ្រដល់ដំណើរការ នៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈនៅក្នុងដំណាក់កាលនីមួយៗ ។ ចាប់តាំងពីការអនុវត្តគម្រោង FMIS ដំហានទី ១ រហូតមកដល់បច្ចុប្បន្ននេះ, ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់នៅតាមអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៃក្រសួង-ស្ថាប័នទាំងអស់, អគ្គនាយកដ្ឋានជំនាញនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, រតនាគាររាជធានី-ខេត្ត និង រដ្ឋបាលរាជធានី-ខេត្តទាំង ២៥ រួមទាំងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបញ្ជូនឯកសារឌីជីថល FMIS Portal ជំនាន់ទី ១ នៅរដ្ឋបាលស្រុកចំនួន ៧៥ និង ឃុំចំនួន ១៨៥ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅតែបន្តមហិច្ឆតាពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធ FMIS បន្ថែមទៀត រហូតដល់អង្គភាពអនុវត្តថវិការដ្ឋនៅគ្រប់ទិសទី ដែលនៅសេសសល់នៅទូទាំងប្រទេស ស្របពេលជាមួយគ្នានឹងការធ្វើបរិវត្តកម្មឌីជីថលថ្មីៗបន្ថែមទៀត ជាមួយនឹងការប្រែក្លាយនីតិវិធីអនុវត្តការងារនានាតាមបែបឌីជីថល ឬ និយាយឱ្យខ្លី លុបបំបាត់នូវការងារដោយដៃលើឯកសារជាក្រដាស មកជាការធ្វើការងារតាមប្រព័ន្ធឌីជីថលទាំងស្រុង ។

ស្របពេលដែលប្រព័ន្ធ FMIS ត្រូវបានពង្រីកការប្រើប្រាស់ជាបន្តបន្ទាប់នៅតាមការដ្ឋានសំខាន់ៗ ដែលជាដំណាក់កាលនីមួយៗនៃនីតិវិធី, ខ្ញុំក៏បានដាក់ចេញនូវបទបញ្ជាបន្ថែមយ៉ាងម៉ឺងម៉ាត់ ឱ្យក្រុមការងារគ្រប់គ្រងគម្រោង FMIS និង ភាគីពាក់ព័ន្ធ **រួមសហការគ្នា** ពន្លឿនការ-សិក្សា និង ជំរុញឱ្យបាន នូវការយកប្រព័ន្ធ FMIS ដែលកំពុងប្រើប្រាស់នេះ មកប្រើប្រាស់ឱ្យបានជាអតិបរមា នូវលទ្ធភាព និង សក្តានុពលនៃមុខងារប្រព័ន្ធ ក្នុងការ **ប្រែក្លាយនីតិវិធីអនុវត្តការងារបច្ចុប្បន្ន ដែលអនុវត្តដោយដៃផង ដោយប្រព័ន្ធផង ទៅជានីតិវិធីថ្មីដែលអនុវត្តតាមប្រព័ន្ធទាំងស្រុង** ដែលមិនមានចរាចរឯកសារជាក្រដាសឡើយ ។ ក្រុមការងារគ្រប់គ្រងគម្រោង FMIS និង ភាគីពាក់ព័ន្ធ ពិតជាបានបំពេញសកម្មភាពការងារ ប្រកបដោយបុរេសកម្ម និង មានឆន្ទៈខ្ពស់ ក្នុងការអនុវត្តតាមបទបញ្ជាខាងលើនេះ ដោយសម្រេចបាននូវសមិទ្ធផលថ្មីបន្ថែម មួយទៀត គឺការដាក់ឱ្យអនុវត្តនីតិវិធីថ្មី សម្រាប់ចំណាយថវិកាចរន្តគ្រប់មុខសញ្ញាតាមប្រព័ន្ធ FMIS ។

ជាក់ស្តែង, នាថ្ងៃនេះ, ការប្រកាសដាក់អនុវត្តនីតិវិធីថ្មី សម្រាប់ចំណាយថវិកាចរន្តគ្រប់មុខសញ្ញា តាមប្រព័ន្ធ FMIS ទាំងស្រុង គឺជាសក្ខីភាពមួយនៃសមិទ្ធផលជាច្រើន ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រេចបាននៅក្នុងកាលៈទេសៈដ៏លំបាកកន្លងមក រួមជាមួយនឹងការ-

ប្តេជ្ញាយ៉ាងម៉ឺងម៉ាត់ ធ្វើជាគំរូអនុវត្តមុនគេ នៅក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទាំងមូល ជាមួយនឹងក្រសួងបរិស្ថាន ។ ក្នុងនាមខ្ញុំជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ខ្ញុំពិតជាមានក្តីសោមនស្ស ដែលបានឃើញនូវលទ្ធផល និង សមិទ្ធផលទាំងអស់នេះ កំពុងជួយជំរុញបន្ថែម ដល់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ផ្តល់ផលចំណេញ និង អត្ថប្រយោជន៍ជាច្រើន ក្នុងការអនុវត្តថវិការដ្ឋ ជាអាទិ៍ ចំណេញពេលច្រើន តាមរយៈការកាត់បន្ថយជំហាន និង ការធ្វើដំណើរ, ការកាត់បន្ថយចំណាយរដ្ឋបាល ដោយមិនមានប្រើប្រាស់ឯកសារជាក្រដាស, ការប្រើប្រាស់ធនធានមនុស្សតិច, ការមិនចាំបាច់មានអ្នករត់ការ, ការមានមូលដ្ឋានតាមដានច្បាស់លាស់ និង ការត្រួតពិនិត្យត្រឹមត្រូវ ព្រមទាំងការផ្តល់នូវមូលដ្ឋាន សម្រាប់ការវាយតម្លៃសមិទ្ធកម្មបន្ថែមទៀត ។

ខ្ញុំសូមឆ្លៀតយកឱកាសនេះ លើកឡើងនូវប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងដាស់តឿនយើងទាំងអស់គ្នាថា «**កែទម្រង់រស់ មិនកែទម្រង់ស្លាប់**» រួមជាមួយនឹងអភិក្រមចំនួន ៥ ចំណុច ក្នុងការអនុវត្តការកែទម្រង់ស៊ីជម្រៅ គឺ «**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**» ដែលក្នុងន័យនេះ ខ្ញុំសង្ឃឹមថា ថ្នាក់ដឹកនាំ និង មន្ត្រីគ្រប់ជាន់ថ្នាក់ ដែលមានតួនាទី និង ភារកិច្ច ក្នុងការបំពេញកិច្ចការហិរញ្ញវត្ថុ និង ថវិកា **ត្រូវត្រៀមខ្លួនក្នុងការផ្លាស់ប្តូរជានិច្ច** និង បំពេញភារកិច្ចរបស់ខ្លួន ឱ្យបានត្រឹមត្រូវ ប្រកបដោយវិជ្ជាជីវៈ ជាពិសេស សម្រាប់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !

បន្ទាប់ពីបានឆ្លងកាត់បទពិសោធនៃវិបត្តិសុខភាពសាធារណៈ ដែលបង្កឡើងដោយការរីករាលដាលនៃជំងឺកូវីដ-១៩ អស់រយៈពេលជាង ២ ឆ្នាំ កន្លងមក, យើងទាំងអស់គ្នាបានឃើញយ៉ាងច្បាស់ អំពីបច្ច័យដែលកើតឡើងបណ្តាលមកពីបញ្ហានេះ ដែលនាំឱ្យមានការពន្យារពេល ឬអាក់ខាន នូវដំណើរការអភិវឌ្ឍលើវិស័យមួយចំនួន; ប៉ុន្តែ, ក៏បានផ្តល់មកនូវកាលានុវត្តភាពមួយចំនួនសម្រាប់កម្ពុជា ក្នុងការបង្ហាញសមត្ថភាពទប់នឹងវិបត្តិនេះ លើឆាកអន្តរជាតិ, ការកសាងភាពធន់ និង ការជំរុញល្បឿននៃការចាប់យកបច្ចេកវិទ្យាឌីជីថលមកប្រើប្រាស់, ទាំងក្នុងវិស័យសាធារណៈ, វិស័យឯកជន និង ក្នុងចំណោមសាធារណជនទូទៅ ។

ផ្អែកតាមនិន្នាការសកល ដែលកំពុងតែស្ថិតនៅក្នុង **បដិវត្តឧស្សាហកម្ម ៤.0** ដោយផ្តោតជាសំខាន់ទៅលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងការធ្វើបរិវត្តកម្មឌីជីថលលើគ្រប់

វិស័យ, រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំ និង សម្រេចដាក់ចេញនូវ **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** ដែលជាមាគ៌ាតម្រង់ទិសមួយដ៏សំខាន់ សម្រាប់គ្រប់តួអង្គដែលមានការពាក់ព័ន្ធ ឱ្យផ្តោតការយកចិត្តទុកដាក់ និង ជំរុញការចាប់យកប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាឌីជីថល ក្នុងការបង្កើនផលិតភាព និង ប្រសិទ្ធភាពការងារ ។ តបតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, **កម្ពុជាត្រូវតែខិតខំសម្រេចបរិវត្តកម្មឌីជីថល ឱ្យខាងតែបាន ទើបអាចជំរុញសង្គម-សេដ្ឋកិច្ចកម្ពុជា ទៅកាន់កម្រិតនៃការអភិវឌ្ឍមួយខ្ពស់ឡើងជាលំដាប់** ។

ក្នុងន័យនេះ, ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកំពុងតែប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនស្រាប់, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្តេជ្ញាបន្តខិតខំពិនិត្យមើលលទ្ធភាពបន្ថែមទៀត ក្នុងការបង្កើននូវតម្លៃបន្ថែមលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះ ដើម្បីរៀបចំមូលដ្ឋានគ្រឹះសម្រាប់ឈានទៅធ្វើបរិវត្តកម្មឌីជីថលជាបណ្តើរៗ ។ តួយ៉ាង, ការផ្តួចផ្តើមរៀបចំនូវនីតិវិធីអនុវត្តការងារថ្មីតាមបែបឌីជីថលទាំងស្រុងក៏ជាចំណែកមួយនៃការចាប់ផ្តើមនៃបរិវត្តកម្មឌីជីថល នៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយប្រើប្រាស់ប្រព័ន្ធ FMIS ជាឧបករណ៍ និង អាចភ្ជាប់ជាមួយប្រព័ន្ធឌីជីថលគាំទ្រផ្សេងៗទៀតជាបន្តបន្ទាប់ ក្នុងការសម្រួលដល់នីតិវិធីអនុវត្តការងារក្នុងក្របខណ្ឌ នៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឆ្លើយតបទៅនឹងគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់នេះ គឺ ប្រសិទ្ធភាព, តម្លាភាព និង គណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ ។

ក្នុងបរិការណ៍នេះ, ការប្រើប្រាស់ប្រព័ន្ធឌីជីថល គឺជាគន្លងការងារថ្មីរបស់រាជរដ្ឋាភិបាលនៅក្នុងការរៀបចំរដ្ឋាភិបាលឌីជីថល ។ ដូច្នេះ, **មន្ត្រីរាជការត្រូវត្រៀមលក្ខណៈឱ្យបានរួចរាល់ក្នុងការរៀនសូត្របន្ថែម និង ចាប់យកឱ្យបាននូវការផ្លាស់ប្តូររបៀបធ្វើការងារថ្មី តាមឱ្យទាន់សម័យកាល និង កាលៈទេសៈនៃការវិវឌ្ឍសង្គម និង សេដ្ឋកិច្ចឌីជីថល** ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !

នាឱកាសនេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការខិតខំរបស់ក្រុមការងារគ្រប់គ្រងគម្រោង FMIS ដែលដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, និង គ្រប់ក្រសួង-ស្ថាប័ន ដែលបានរួមសហការជាកម្លាំងរួមមួយ ក្នុងការកសាងបាននូវសមិទ្ធផលជាច្រើនកន្លងមក រួមទាំងសមិទ្ធផលដែលសម្រេចបានក្នុងថ្ងៃនេះ និង សូមថ្លែងអំណរគុណដល់គ្រប់

ភាគីពាក់ព័ន្ធ ជាពិសេស ដៃគូអភិវឌ្ឍន៍ដែលបានចូលរួមគាំទ្រ, ទាំងជាបច្ចេកទេស និង ជាហិរញ្ញប្បទានក្នុងពេលកន្លងមក ។ ខ្ញុំក៏សូមលើកទឹកចិត្តដល់គ្រប់តួអង្គពាក់ព័ន្ធ ឱ្យបន្តកិច្ចសហប្រតិបត្តិការនេះជាបន្តបន្ទាប់ទៀត ដើម្បីរួមគ្នានាំកម្ពុជាឈានឆ្ពោះទៅរកភាពកាន់តែរីកចម្រើនជាលំដាប់ តទៅមុខទៀត ។

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ព្រមទាំងដៃគូអភិវឌ្ឍន៍ ដែលបានចំណាយពេលដ៏មានតម្លៃ ចូលរួមក្នុងកម្មវិធីនាថ្ងៃនេះ ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជូនឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជួបប្រទះតែនឹងសេចក្តីសុខ, សេចក្តីចម្រើន, និង សូមប្រកបតែនឹងពុទ្ធពរទាំង ៤ ប្រការ គឺ **អាយុ, វណ្ណៈ, សុខៈ,** និង **ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ និង សូមជៀសឆ្ងាយពីជំងឺកូវីដ-១៩ ។

ខ្ញុំសូមប្រកាសជាផ្លូវការនូវ «**ការដាក់ឱ្យអនុវត្តនីតិវិធីថ្មីសម្រាប់ចំណាយថវិកាចរន្ត ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងបរិស្ថាន តាមប្រព័ន្ធ FMIS ទាំងស្រុង**» ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ !**